Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ មគ្គុទេសក៍

## របស់គម្រោងឈេនសម្រាប់ ការអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារកសិកម្ម



## ការផលិតវីដេអូរបស់កសិករ សម្រាប់ការផ្សព្វផ្សាយតាមឌីជីថល

ការណែនាំជាក់ស្តែងអំពីរបៀបបង្កើត និង ចែករំលែកវីដេអូដែលមានគោលដៅជាកសិករ ក្នុងទម្រង់នៃការផ្សព្វផ្សាយតាមបែបឌីជីថល ដ៏មានប្រសិទ្ធភាព

CHAIN
SNV
swisscontact

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

# សៀវភៅ មគ្គុទេសក៍

## របស់គម្រោងឈេនសម្រាប់ ការអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារកសិកម្ម

SNV

swisscontact

## គម្រោងឈេន

### សៀវភៅមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារកសិកម្ម

# ការផលិតវីដេអូរបស់កសិករសម្រាប់ការផ្សព្វផ្សាយតាមឌីជីថល


ចងក្រងដោយ៖
លោក រិត អូរើម៉ាស៍ លោក សៀងវ៉ាន់ស៊ីថា លោក លឹម សុគន្ធដារុណ លោកស្រី ឃឹម គឹមបួយ



**សូមថ្លែងអំណរគុណចំពោះអ្នកពិនិត្យ និងកែសម្រួល៖**

លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគិន
លោកស្រី ម៉ារិគិ វ៉ាន់ស៊្បី
លោក រិគ វ៉ាន់ គូលេន
លោក ហែម សុវណ្ណារិទ្ធ
បណ្ឌិត សុខ គឹមឈិន
លោក ឱ ធី
លោក អ៊ុក វណ្ណារ៉ា

**រចនា និងរៀបចំបោះពុម្ពផ្សាយ៖** ក្រុមហ៊ុន អិម. អ. អេ ឌីហ្សាញ
**រៀបចំរូបភាព៖** គម្រោងឈេន
**អ្នកពិនិត្យផ្ទៀងផ្ទាត់៖** លោក រ៉ូណាល់ដូ ម៉ុងតេកាល់វ៉ូ
**បកប្រែជាភាសាខ្មែរ៖** លោក ត្រាយ ប៊ុនថន



**គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ (ឈេន) អេសអិនវី កម្ពុជា និងអគ្គនាយកដ្ឋានកសិកម្ម**

អ៊ីមែល៖ horticulturecambodia@gmail.com
វិបសាយ៖ https://web.maff.gov.kh
ហ្វេសប៊ុក៖ @សាកវប្បកម្មកម្ពុជា Horticulture in Cambodia

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

# បុព្វបទ

វិស័យកសិកម្មនៅប្រទេសកម្ពុជាបានបង្ហាញការបន្តរីកលូតលាស់ទាំងផលិតកម្ម និងការនាំចេញទោះបី ជាមានការរីករាលដាលនៃជំងឺកូវីត១៩។ ទោះបីយ៉ាងណាក៏ដោយ ភាពក្រីក្រនៅតែជាកត្តាចំបងកើតមានឡើងនៅតំបន់ជនបទ ដែលប្រហែលជា៨០% នៃប្រជាជនក្រីក្រចំនួន ២,៥លាននាក់ កំពុងរស់នៅក្នុងតំបន់ជនបទ។ ផលិតភាពទាបនៃកសិករខ្នាតតូចកម្ពុជា បានកើតឡើងដោយការប្រើប្រាស់នៅមានកម្រិតនូវធាតុចូលកសិកម្ម ដែលមានគុណភាព ការអនុវត្តតាមស្តង់ដាបច្ចេកទេស និងនវានុវត្តន៍ ព្រមទាំងឱកាស និងព័ត៌មានទីផ្សារ។ សម្ពាធនៃធនធានធម្មជាតិ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមបន្ថែមទៀត។ ចំណែកការចូលរួមក៏នៅមានកម្រិតពីសំណាក់វិស័យឯកជន លើសេវាផ្សព្វផ្សាយកសិកម្ម និងកិច្ចសហការខ្សោយជាមួយតួអង្គមកពីវិស័យសាធារណៈ បានរាំងការអភិវឌ្ឍភាពរីកចម្រើនរបស់កសិករខ្នាតតូច។ កម្ពុជាពុំទាន់បានផ្គត់ផ្គង់បន្លែក្នុងស្រុកគ្រប់គ្រាន់នៅឡើយ ម្យ៉ាងវិញទៀត កំណើនសេដ្ឋកិច្ចរហ័សបានបង្ហាញនូវតម្រូវការកាន់តែខ្ពស់សម្រាប់ការបរិភោគបន្លែ និងផ្លែឈើដែលសុវត្ថិភាព និងគុណភាពល្អ។ កត្តានេះជាឱកាសដ៏មានតម្លៃរបស់កសិករខ្នាតតូច និងអ្នកកែច្នៃ ជាពិសេសស្ត្រី ក្នុងការបង្កើនប្រាក់ចំណូល និងសន្តិសុខស្បៀង។ ជាងនេះទៅទៀត ភាពប្រសើរឡើងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ បានជំរុញការបំលាស់ទីរបស់ប្រជាជនក្រីក្រជនបទ ដោយផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានទីផ្សារចម្រុះ និងឱកាសការងារជាច្រើន។

ឆ្លើយតបទៅនឹងបញ្ហា និងឱកាសទាំងនេះ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) បានអភិវឌ្ឍគម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ ដែលហៅកាត់ថា (គម្រោងឈេន) ជាកម្មវិធីអភិវឌ្ឍន៍សម្រាប់រយៈពេលប្រាំបីឆ្នាំ (២០១៤ - ២០២២) ដោយសហការជិតស្និទជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងបណ្តាខេត្តគោលដៅ។ គម្រោងឈេនបានប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍន៍ទីផ្សារមួយដែលមានគោលបំណងពង្រឹងការចូលរួមរបស់កសិករក្រីក្រ (ផ្តោតសំខាន់លើស្ត្រី) នៅក្នុងទីផ្សារដើម្បីធានានូវលទ្ធភាពប្រើប្រាស់ធាតុចូលកសិកម្ម និងសេវាកម្មបានប្រសើរ និងទទួលបានចំណូលខ្ពស់។ កត្តាគន្លឹះនៃវិធិសាស្ត្រនេះគឺជាដំណើរការសម្របសម្រួលមួយ សម្រាប់ទាក់ទាញការចូលរួមពីបណ្តាដៃគូឯកជន និងសាធារណៈ ព្រមទាំងអង្គការសង្គមស៊ីវិលក្នុងការផ្តល់ជូននូវទំនិញ និងសេវាកម្មនានា ទាំងធាតុចូល និងផលិតផលកសិកម្មនៃច្រវាក់តម្លៃសាកវប្បកម្ម (ឧទាហរណ៍៖ ការផ្សព្វផ្សាយ ធាតុចូលកសិកម្ម ការរៀបចំទីផ្សារ និងព័ត៌មានទីផ្សារ) ដែលសាកសម និងបំពេញចំតម្រូវការកសិករក្រីក្រ និងអ្នកកែច្នៃ។ ឆ្លងកាត់រយៈពេល៨ឆ្នាំ យើងអាចសម្រេចបានលទ្ធផលប្រកបដោយផ្លែផ្កា។ ផលិតកម្មលើដំណាំបន្លែរបស់កម្ពុជាបានកើនឡើងគួរអោយកត់សម្គាល់ក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយនេះ និងបច្ចុប្បន្នបានគ្របដណ្តប់ ៦៨% នៃតម្រូវការទីផ្សារក្នុងស្រុក (៧០០.០០០តោនក្នុងឆ្នាំ២០២០) ប្រៀបធៀបនឹង៤២២.០០០តោន ក្នុងឆ្នាំ២០១៣។ សមិទ្ធិផលដ៏អស្ចារ្យ!

សៀវភៅមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្មនេះ គឺជាកាប្រមូលផ្តុំឧបករណ៍ គោលការណ៍ ការប្រតិបត្តិ និងវិធីសាស្ត្រនានា ដែលបានអភិវឌ្ឍក្នុងអំឡុងពេលអនុវត្តន៍គម្រោងឈេន។ សៀវភៅនេះនឹងផ្តល់ជាឯកសារយោងសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម ដែលមកពីវិស័យឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិលជាដើម។ ជាងនេះទៅទៀត វាក៏ជាសៀវភៅណែនាំមួយសម្រាប់ឆ្ពោះទៅរកនិរន្តរភាពដែលជាស្នូលដ៏សំខាន់សម្រាប់គម្រោងឈេនដោយមានគោលបំណងពង្រឹង ប្រព័ន្ធទីផ្សារសាកវប្បកម្ម និងសមត្ថភាពនៃតួអង្គគ្រប់វិស័យដើម្បីផ្តល់សេវាកម្មទៅកសិករគោលដៅ។ បណ្តាញទំនាក់ទំនង គោលនយោបាយ និងប្រព័ន្ធទីផ្សារដែលបានបង្កើតឡើង នឹងបន្តដំណើរជាតួអង្គពាក់ព័ន្ធគ្រប់វិស័យ ចំណែកឯកសិករនឹងអាចឈានដល់កម្រិតអប្បបរមា-សមស្របមួយ ដើម្បីក្លាយជាទីផ្សារដែលទទួលបានប្រាក់ចំណេញ និងអាចទ្រទ្រង់ខ្លួនឯងបាន។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម អាជ្ញាធរដែនដីថ្នាក់ខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការអភិវឌ្ឍន៍ហូឡង់ (SNV) ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់កិច្ចសហប្រតិបត្តិការដ៏ឥតខ្ចោះ និងសម្រាប់ការរួមចំណែកដ៏មមាញឹកដល់ការអនុវត្តនៃគម្រោងឈេន។

មាគុស៍ ប៉័រលី (Markus Buerli)
នាយក នៃកិច្ចសហប្រតិបត្តិការ

# មគ្គុទេសក៍ផ្សេងៗទៀតមាននៅក្នុងសៀវភៅនេះ

- សេចក្តីផ្តើមសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ
- ការសម្របសម្រួលការបង្កើតបណ្តុំកសិ-ធុរកិច្ច
- ការសម្របសម្រួលទំនាក់ទំនងអាជីវកម្មទៅអាជីវកម្ម (B2B)
- កម្មវិធីបំប៉នកសិករគម្រូ
- កម្មវិធីជំរុញអាជីវកម្មជនបទ
- ការបង្កើតគម្រោងថវិកាសម្រាប់ដំណាំ
- ដំណោះស្រាយទឹក និងអាកាសធាតុឆ្លាតវៃសម្រាប់វិស័យសាវប្បកម្ម

# តារាងមាតិកា


១. សេចក្តីផ្តើម ១

២. សារតា ២

៣. ទិដ្ឋភាពនៃវិធីសាស្ត្រ ៤

៤. ការណែនាំជាជំហានៗ ៥

៤.១ ប្រភពព័ត៌មាន និងការស្ទង់មតិតាមបណ្តាញឌីជីថល ៦

៤.២ ផលិតវីដេអូអប់រំក្នុងភាពជាដៃគូជាមួយវិស័យឯកជន ១១

៤.៣ ការបកប្រែ / កែសម្រួលវីដេអូដែលមានស្រាប់ ១៣

៤.៤ បណ្តុះបណ្តាលកសិករក្នុងស្រុក និងបុគ្គលិកផ្នែកបផ្សព្វផ្សាយដើម្បីផលិតវីដេអូ ១៤

៤.៥ ការប្រកួតប្រជែងវីដេអូ ១៨

៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ១៨

ឧបសម្ព័ន្ធ ១៩

# ១. សេចក្តីផ្តើម

គម្រោងសាកវប្បកម្មកម្ពុជា ដើម្បីបង្កើនប្រាក់ចំណូល និងអាហារូបត្ថម្ភ ( ឈេន ) បានបង្កើតសៀវភៅមគ្គុទេសន៍ ( HTGs ) ដែលមានន័យថាជាសៀវភៅណែនាំដែលអាចយកទៅអនុវត្តតាម និងផ្តល់ព័ត៌មានសម្រាប់អ្នកដែលមានបំណងចង់ចម្លង និងអភិវឌ្ឍបន្ថែមទៀតនូវវិធីសាស្រ្តជោគជ័យដែលបានប្រើក្នុងដំណាក់កាលទាំងបីនៃឈេន។ យើងសង្ឃឹមថាសៀវភៅមគ្គុទេសន៍ ( HTGs ) ទាំងនេះនឹងមានប្រយោជន៍សម្រាប់អង្គការជាច្រើននៅទូទាំងពិភពលោក ជាពិសេសអ្នកដែលចូលរួមក្នុងគម្រោងអភិវឌ្ឍន៍កសិកម្មដែលអនុវត្តវិធីសាស្រ្តអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ ( សូមមើលប្រអប់ទី ១ )។ ទោះជាយ៉ាងណាក៏ដោយ យើងបានសរសេរសៀវភៅមគ្គុទេសន៍ ( HTGs ) ជាមួយអ្នកពាក់ព័ន្ធកម្ពុជាដែលភាគច្រើនគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( MAFF ) អគ្គនាយកដ្ឋានកសិកម្ម ( GDA ) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ( PDAFFs ) និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។

## ប្រអប់ទី១៖ អភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ (MSD)

វិធីសាស្រ្ត MSD គ្របដណ្តប់ប្រព័ន្ធទាំងមូលដែលនៅជុំវិញទីផ្សារ។ ក្នុងករណីវិស័យសាកវប្បកម្ម ទិដ្ឋភាពរួមនេះរួមបញ្ចូលទាំងអ្នកចូលរួមទីផ្សារពាក់ព័ន្ធទាំងអស់ ( «តួអង្គ» ឬ «អ្នកលេង» ): កសិករដែលដាំដំណាំ អ្នកលក់រាយដែលលក់គ្រាប់ពូជ និងធាតុចូលផ្សេងទៀតដល់កសិករ ឈ្មួញដែលទិញដំណាំ អ្នកលក់នៅផ្សារដែលលក់បន្លែឲ្យអ្នកប្រើប្រាស់។ វាក៏អាចរួមបញ្ចូលសេវាកម្មដែលគាំទ្រទីផ្សារចំបង ដូចជាភ្នាក់ងារផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាលដែលផ្តល់ដំបូន្មានដល់កសិករ និងស្ថាបនទីផ្សារក្នុងស្រុកដែលបង្កើតកន្លែងសម្រាប់អ្នកទិញ និងអ្នកលក់ដើម្បីជួប។

MSD មានគោលបំណងដោះស្រាយភាពក្រីក្រដោយការកែលម្អការអនុវត្តទីផ្សារក្នុងលក្ខណៈរួមបញ្ចូល ជាពិសេសដោយការកែប្រែការលើកទឹកចិត្ត និងលក្ខណៈរបស់អាជីវកម្ម និងតួអង្គទីផ្សារផ្សេងទៀតដើម្បីធានាបាននូវការផ្លាស់ប្តូរទ្រង់ទ្រាយធំដែលយូរអង្វែង និងមានប្រយោជន៍។

សៀវភៅមគ្គុទេសន៍ ( HTG ) នេះផ្តោតលើរបៀបបង្កើតវីដេអូតាមរយៈការផ្សព្វផ្សាយ ឌីជីថលនៅក្នុងសាកវប្បកម្ម។ ជាលទ្ធផលនៃការរឹតបន្តឹងដែលបានដាក់កំទ្បុងពេលជំងឺរាតត្បាត Covid-19 និងតាមរយៈការប្រើបច្ចេកវិទ្យាឌីជីថលដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ការងារនៅគ្រប់ទីកន្លែងបានផ្លាស់ប្តូរទៅរកវិធីថ្មីនៃការទំនាក់ទំនង រួមទាំងការប្រជុំ និងការបណ្តុះបណ្តាលតាមអ៊ីនធឺណិត។ ជាមួយគ្នានេះ ភាពអាចរកបានជាសកលនៃទូរសព្ទស្មាតហ្វូន និងអ៊ីនធឺណិតបានជំរុញឱ្យមានការកើនឡើងនៃការប្រើប្រាស់វេទិកាអនឡាញ កម្មវិធី និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ វិស័យកសិកម្មរបស់កម្ពុជាបានមើលឃើញពីការដាក់ឱ្យប្រើប្រាស់កម្មវិធីជាច្រើនដូចជា ចំការ (Chamka) Sokapheap Domnam TonleSap និង Angkor Salad ដែលត្រូវបានផ្តល់មូលនិធិ និងគាំទ្រដោយគម្រោងអភិវឌ្ឍន៍ដើម្បីបង្កើនសេវាកម្មដល់កសិករ និងភ្ជាប់ពួកវាទៅកាន់ភាគីពាក់ព័ន្ធផ្សេងៗ។



នៅក្នុងប្រទេសកម្ពុជា ការកើនឡើងនៃតម្រូវការបន្លែដាំដុះក្នុងស្រុកបាននាំឱ្យមានការកើនឡើងនៃផលិតកម្មបែបអាជីវកម្ម ដែលជាហេតុជំរុញឱ្យមានតម្រូវការសម្រាប់ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រសាកវប្បកម្ម។ ទោះបីជាការប្រើប្រាស់កម្មវិធីទូរស័ព្ទមិនទាន់ជាដំណោះស្រាយទូទៅសម្រាប់កសិករកម្ពុជាដែលស្វែងរកព័ត៌មាន និងចំណេះដឹងក៏ដោយ ក៏មាននិន្នាការកើនឡើងក្នុងចំណោមកសិករជំនាន់ក្រោយក្នុងការទាញយកអត្ថប្រយោជន៍ពីការរៀនតាមឌីជីថល។ នៅក្នុង HTG នេះ យើងពណ៌នាអំពីការរកឃើញរបស់យើងមួយចំនួនអំពីឧបករណ៍ឌីជីថលថ្មីដែលមានសម្រាប់កសិករ – ប្រជាប្រិយភាព ភាពស្គាល់ និងមុខងាររបស់ពួកគេ–ហើយស្នើវិធីជាក់ស្តែងដើម្បីបង្កើនចំណេះដឹងរបស់កសិករតាមរយៈមធ្យោបាយឌីជីថល។

[9] DataReportal. (2022). Digital 2022: Cambodia. https://datareportal.com/reports/digital-2022-cambodia

# ២. សាវតា

ដំណាំសាកវប្បកម្ម គឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចកសិកម្មនៃប្រទេសកម្ពុជា ដោយសារការកើនឡើងនៃការប្រើប្រាស់ផ្លែឈើ និងបន្លែយ៉ាងឆាប់រហ័ស។ រហូតមកដល់ពេលថ្មីៗនេះ ជាង 50% នៃបន្លែទាំងអស់ត្រូវបាននាំចូលពីប្រទេសជិតខាង ដែលបំពាក់ដោយបច្ចេកវិជ្ជាផលិតកាន់តែប្រសើរ និងមានសមត្ថភាពផលិតពេញមួយឆ្នាំ ហើយដូច្នេះផ្តល់នូវផលិតផលដែលមានតម្លៃប្រកួតប្រជែង។ ទោះជាយ៉ាងនេះក្តី បន្លែដែលនាំចូលមានផ្ទុកបរិមាណសំណល់ថ្នាំពុលកសិកម្មច្រើន ដូច្នេះហើយបានជាមានការបារម្ភអំពីបញ្ហាសុវត្ថិភាពចំណីអាហារ។ គម្រោងឈេនបានធ្វើការលើការលើកកម្ពស់បន្លែដែលផលិតក្នុងស្រុកប្រកប ដោយសុវត្ថិភាពនៅក្នុងខេត្តចំនួនបួនភាគខាងជើងនៃប្រទេសកម្ពុជា (ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ)។

វាត្រូវបានគេរាយការណ៍ថាមានអ្នកប្រើប្រាស់អ៊ីនធឺណិតចំនួន 13.4 លាននាក់នៅក្នុងប្រទេសកម្ពុជាក្នុងខែមករា ឆ្នាំ2022 ឬ 78.8% នៃចំនួនប្រជាជនសរុប។ 12.6 លាននាក់ (73.9% នៃចំនួនប្រជាជន) ក៏ជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។[1]

## បទពិសោធន៍ជាមួយគម្រោងឈេន



### កសិករអ្នកដាំបន្លែ

លោកស្រី ធិន បុត្រ ជាស្ត្រីមានអាយុ៥៦ឆ្នាំ រស់នៅឃុំឬស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ នាងគឺ ជាកសិករម្នាក់ក្នុងចំណោមកសិករដែលត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គបណ្តុះបណ្តាលវីដេអូដែលឧបត្ថម្ភដោយ គម្រោងឈេន។ លោកស្រីធ្លាប់លក់បន្លែដល់អ្នកប្រើប្រាស់ក្នុងភូមិរបស់គាត់ និងតាមរយៈអ្នកប្រមូលទិញក្នុងស្រុក។ យ៉ាងណាមិញ បន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាលមក លោកស្រីចាប់ផ្តើមផ្សព្វផ្សាយផលិតផលរបស់ខ្លួនតាមរយៈបណ្តាញសង្គម។

*« មុនពេលចូលរួមវគ្គបណ្តុះបណ្តាល ខ្ញុំក៏មិនចេះថតរូបឲ្យបានស្អាតដែរ។ ឥឡូវនេះខ្ញុំដឹងពីរបៀបថតរូបដែលមានគុណភាពខ្ពស់ ហើយខ្ញុំក៏អាចបង្កើតវីដេអូផ្សព្វផ្សាយផងដែរ។ ប្តីខ្ញុំ និងខ្ញុំបង្ហោះវានៅលើ Facebook ដើម្បីផ្សព្វផ្សាយផលិតផលរបស់យើង។»*

ជាលទ្ធផល ប្រាក់ចំណូលរបស់គាត់បានកើនឡើងគួរឱ្យកត់សម្គាល់ពី 200,000 រៀល ដល់ 1,000,000 រៀលក្នុងមួយថ្ងៃ។



### មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លោក សំ បុង ជាមន្ត្រីនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ។ គាត់បានទទួលការបណ្តុះបណ្តាលស្តីពីការបង្កើតវីដេអូក្នុងគម្រោងឈេនដំណាក់កាលទី៣។ «ក្នុងនាមជាមន្ត្រីផ្នែកផ្សព្វផ្សាយ ខ្ញុំព្យាយាមស្វែងរកយុទ្ធសាស្តល្អៗដើម្បីផ្ញើសារទៅកសិករ»។

*« បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការផលិតវីដេអូ ខ្ញុំមានគំនិតថ្មីៗ និងអាចបញ្ចូលទស្សនៈទានអំពីវីដេអូក្នុងការងារប្រចាំថ្ងៃរបស់ខ្ញុំ »។*

គាត់បន្ថែមថា ការចែករំលែករូបភាព និងវីដេអូនៅលើបណ្តាញសង្គមកាន់តែមានប្រជាប្រិយភាពក្នុងចំណោមកសិករ។ លោកបន្តថា៖ «ការផ្ទេរចំណេះដឹង និងបច្ចេកទេសកសិកម្មទៅកសិករមិនងាយស្រួលទេ ប៉ុន្តែការចែករំលែករូបភាព និងវីដេអូគឺ ជាយុទ្ធសាស្ត្រដ៏ល្អ។ ពួកគេរីករាយក្នុងការទស្សនា ដូច្នេះពួកគេបង្កើតវិធីសាស្រ្តកសិកម្មកាន់តែងាយស្រួលក្នុងការរៀន និងទទួលយក។



## ដៃគូឯកជន

លោក កែវ ច័ន្ទដារី អគ្គនាយកក្រុមហ៊ុន វ៉ាឡាំង ផានី បានលើកឡើងថា «ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រយ៉ាងខ្លាំងដល់ក្រុមហ៊ុនរបស់ខ្ញុំក្នុងការផលិតវីដេអូចំនួន 15 ។ ខ្ញុំចូលចិត្តវាខ្លាំងណាស់ ហើយវីដេអូទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនរបស់ខ្ញុំក្នុងការកសាងទំនុកចិត្ត និងសញ្ញាពាណិជ្ជដល់អតិថិជនរបស់យើង ហើយក៏អាចចែករំលែកទិដ្ឋភាពផ្នែកបច្ចេកទេសដល់កសិករផងដែរ។ ជាពិសេស ចម្ការបង្ហាញអាចផ្តល់លទ្ធផលល្អក្នុងការកំណត់ចន្លោះគុម្ពដំណាំសមស្រប ការដាក់ជី និងការកែលម្អរូបរាងផ្លែឪឡឹកលឿង។ លទ្ធផលនៃការធ្វើចម្ការបង្ហាញទុកជាភ័ស្តុតាងសម្រាប់ក្រុមហ៊ុនខ្ញុំក្នុងការចែករំលែក និងណែនាំដល់កសិករដាំឪឡឹកលឿងផ្សេងទៀតក្នុងប្រទេសកម្ពុជាតាមរយៈវីដេអូ។»



## អ្នកបង្ហាត់ការផលិតវីដេអូ

លោក ប៉ូយ ឈុនលី អាយុ ៣៩ឆ្នាំ ជាជាងថតរូប បានទទួលសញ្ញាប័ត្រផ្នែកគំនូរជីវចល 2D ពីប្រទេសបារាំង។ ដោយបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការផលិតវីដេអូសម្រាប់សេវាកម្មផ្សព្វផ្សាយកសិកម្ម គាត់ត្រូវបានចុះកិច្ចសន្យាជាគ្រូបណ្តុះបណ្តាលសម្រាប់ឈេន។ ដោយមានសុទិដ្ឋិនិយម លោក ឈុនលី កត់សម្គាល់ថា ការផ្សព្វផ្សាយព័ត៌មានណែនាំសំខាន់ៗដល់កសិករដោយផ្ទាល់តាមរយៈសំឡេង វីដេអូ និងរូបភាពគឺ អាចធ្វើទៅបានសូម្បីតែនៅតំបន់ដាច់ស្រយាលក៏ដោយ។

*គាត់និយាយថា « វីដេអូអាចជួយសម្រួលដល់ការទទួលបានព័ត៌មានដែលកសិករត្រូវការពិតប្រាកដ »។*
*« ហើយពួកគេបំផុសគំនិតកសិករឱ្យមានភាពច្នៃប្រឌិតក្នុងដំណើរការផលិតរបស់ពួកគេផ្ទាល់។ »*

គាត់កត់សម្គាល់ថាវីដេអូ និងរូបភាពអាចត្រូវបានប្រើប្រាស់ជាឧបករណ៍សិក្សាឯករាជ្យ ឬគាំទ្រដោយបច្ចេកទេសផ្សេងទៀត។ ពួកគេអាចដើរតួជាសម្ភារៈសិក្សាសម្រាប់កសិករ ហើយពួកគេអាចគាំទ្រការងាររបស់កម្មករផ្នែកផ្សព្វផ្សាយកសិកម្ម។ ជាពិសេសវីដេអូគឺមានភាពចម្រុះ ហើយអាចត្រូវបានកែសម្រួលយ៉ាងងាយស្រួលឱ្យសមនឹងភាសាក្នុងស្រុកដោយបន្ថែមចំណងជើងរងឬការបញ្ចូលសំឡេង។

# ៣. ទិដ្ឋភាពនៃវិធីសាស្ត្រ

## តើអ្វីជាបញ្ហា ?

កសិករមានធនធានសិក្សា និងការផ្សព្វផ្សាយនៅមានកម្រិត ដើម្បីបង្កើនចំណេះដឹងអំពីបច្ចេកទេសកសិកម្ម និងការច្នៃប្រឌិត។ កសិករជាច្រើនអនុវត្តទំនៀមទម្លាប់ប្រពៃណីដោយផ្អែកលើបទពិសោធន៍របស់ពួកគេ និងការចែករំលែកពីមិត្តភ័ក្តិ (ការរៀនសូត្រពីអ្នកជិតខាង និងសាច់ញាតិ)។ ការផ្សព្វផ្សាយការអនុវត្តបែបប្រពៃណីត្រូវបានផ្តល់ដោយតួអង្គមួយចំនួន ដូចជារដ្ឋាភិបាលថ្នាក់ខេត្ត (PDAFF) អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន (ភាគច្រើនជាក្រុមហ៊ុនលក់ធាតុចូលដែលផ្តល់គ្រាប់ពូជ និងផលិតផលការពារដំណាំ)។ ចម្ការបង្ហាញដែលគ្រប់គ្រងដោយកសិករ និងសាលាកសិករ គឺជាប្រភេទដែលពេញនិយម និងមានប្រសិទ្ធភាពបំផុតនៃកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ។ ដោយសារតែការរឹតត្បិត Covid-19 ទម្រង់បែបប្រពៃណីនៃការផ្សព្វផ្សាយទាំងនេះមិនអាចធ្វើទៅបានក្នុងរយៈពេលយូរនោះទេ ដោយសារការប្រជុំត្រូវបានលុបចោល ហើយការធ្វើដំណើរត្រូវបានហាមឃាត់។ ជំនួសមកវិញ យើងបានព្យាយាមប្រើប្រាស់បណ្តាញឌីជីថល ដើម្បីផ្តល់សារបន្ថែមតាមរយៈស្មាតហ្វូន។

ការផ្សព្វផ្សាយតាមឌីជីថលមានអត្ថប្រយោជន៍មួយចំនួនលើវិធីសាស្ត្រផ្សព្វផ្សាយបែបរូបវ័ន្ត (ទល់មុខគ្នា) រួមទាំងការចំណាយទាប សក្តានុពលសម្រាប់ការធ្វើការពង្រីកដ៏ធំ និងលទ្ធភាពទទួលបានព័ត៌មានប្រកប ដោយសមធម៌ជាងមុន។ គុណវិបត្តិរួមមានអសមត្ថភាពក្នុងការផ្តល់ដំបូន្មានតាមតម្រូវការ និងការបង្ហាញជាក់ស្តែង។ វីដេអូខ្លីៗ ដើម្បីបង្ហាញអំពីបច្ចេកវិទ្យាកសិកម្ម និងបច្ចេកទេសគ្រប់គ្រងដំណាំ ប្រហែលជាជម្រើសដ៏ល្អបំផុតសម្រាប់ការធ្វើចម្ការបង្ហាញជាក់ស្តែង។ ជាការពិតណាស់ វីដេអូកំពុងត្រូវបានប្រើប្រាស់កាន់តែខ្លាំងឡើងសម្រាប់ការផ្សព្វផ្សាយកសិកម្មនៅក្នុងប្រទេសជាច្រើន ដោយទទួលបានលទ្ធផលល្អ។[២]

កម្មវិធីឌីជីថលជាច្រើនដែលត្រូវបានផលិតសម្រាប់ការងារកសិកម្មមាននៅក្នុងប្រទេសកម្ពុជា។ ភាគច្រើននៃកម្មវិធីទាំងនេះត្រូវបានផ្តួចផ្តើម និងបង្កើតឡើងដោយគម្រោងអភិវឌ្ឍន៍ ហើយជារឿយៗឈប់ដំណើរការនៅពេលដែលមូលនិធិគម្រោងអស់។ កម្មវិធីមួយចំនួនមានគំរូអាជីវកម្មប្រកបដោយនិរន្តរភាពជាងមុន ដែលស្ថិតនៅក្រោមប្រតិបត្តិការរបស់ពួកគេ។ យើងមិនបានដឹងថាផលិតផលឌីជីថល និងបណ្តាញទំនាក់ទំនងណាដែលកសិករប្រើប្រាស់ និង/ឬមានសិទ្ធិចូលប្រើប្រាស់នោះទេ ហើយក្នុងទម្រង់ផ្សព្វផ្សាយដែលការផ្ញើសារអាចត្រូវបានផ្តល់ជូនយ៉ាងមានប្រសិទ្ធភាពបំផុត។

## តើយើងរំពឹងថានឹងសម្រេចបានអ្វីខ្លះ ?

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ យើងចង់ដឹងថាតើបណ្តាញណាដែលកសិករចូលចិត្ត និងរៀនពីសូត្រ ហើយប្រធានបទណាដែលមានការចាប់អារម្មណ៍បំផុតសម្រាប់ពួកគេ។ យើងក៏ចង់បង្កើតវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការចំណាយដើម្បីបង្កើតវីដេអូសម្រាប់ការពង្រីកកសិករ។ នៅទីបំផុត យើងសង្ឃឹមថាកសិករនឹងទទួលបានប្រភពថ្មីនៃព័ត៌មានឌីជីថល ដើម្បីស្វែងយល់ ពិសោធន៍ និងទទួលយកបច្ចេកវិទ្យាដែលប្រសើរឡើង។ យើងក៏សង្ឃឹមផងដែរថា កសិករ និងបុគ្គលិកអាចនឹងអភិវឌ្ឍសមត្ថភាពថតវីដេអូ ដើម្បីបង្កើនការចែករំលែក និងការសិក្សា ហើយចំនួនវីដេអូកសិកម្ម ឬសាកវប្បកម្មដែលអាចប្រើបានដោយសេរីជាភាសាខ្មែរនឹងកើនឡើង។

## តើមានដំណោះស្រាយ/វិធីសាស្ត្រអ្វីខ្លះ ?

យើងបានស្ទង់មតិសំណាកកសិករសាកវប្បកម្មដែលផ្តោតលើអាជីវកម្ម ដើម្បីប្រមូលព័ត៌មានអំពីប្រភពនៃការសិក្សាកសិកម្ម និងបណ្តាញឌីជីថលដែលពួកគេប្រើប្រាស់។ ទិន្នន័យដែលប្រមូលបានក៏អនុញ្ញាតឱ្យយើងកំណត់ថាប្រធានបទណាដែលចាប់អារម្មណ៍បំផុតសម្រាប់កសិករទាំងនេះ។ បន្ទាប់មក យើងបង្កើតភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីផលិតវីដេអូលើប្រធានបទទាំងនេះ។ នេះពាក់ព័ន្ធនឹងការជួលអ្នកផលិតវីដេអូដែលមានបទពិសោធន៍ ដើម្បីបណ្តុះបណ្តាលកសិករ ក៏ដូចជាគម្រោង និងបុគ្គលិក PDAFF អំពីរបៀបថត និងផលិតវីដេអូសាមញ្ញនៅលើស្មាតហ្វូនរបស់ពួកគេ។

[២] Fabregas, R., Kremer , M., & Schilbach, F. (2019). Realizing the potential of digital development: The case of agricultural advice. Science, 366(6471). doi: 10.1126/science.aay3038

# ៤. ការណែនាំជាជំហានៗ



### ១ ជំហានទី ១៖ ការស្ទង់មតិតាមបណ្តាញឌីជីថល និងគម្លាតចំណេះដឹង

- ការស្រាវជ្រាវលើគុ
- ការរចនាកម្រងសំណួរ
- ការប្រមូលទិន្នន័យ
- ការវិភាគទិន្នន័យ ការពិភាក្សា និងរបាយការណ៍
- ការបោះពុម្ពផ្សាយ



### ២ ជំហានទី ២៖ ភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីផលិតវីដេអូ

- ឯកសារទស្សនៈទាន និងកិច្ចព្រមព្រៀង
- ផែនការការងារ និងថវិកា
- ការសរសេរស្រ្គីប
- ការថតភាពយន្ត និងការកែសម្រួលវីដេអូ
- ការត្រួតពិនិត្យគុណភាព
- ការផ្សព្វផ្សាយ



### ៣ ជំហានទី៣៖ បណ្តុះបណ្តាលកសិករលើជំនាញបង្កើតវីដេអូ

- ផែនការបណ្តុះបណ្តាល
- ការបណ្តុះបណ្តាលវីដេអូដោយដៃ
- ហាត់ធ្វើវីដេអូ



### ៤ ជំហានទី ៤: ការប្រកួតប្រជែងវីដេអូ

ការប្រកួតប្រជែងជាមួយនឹងរង្វាន់ដើម្បីជំរុញការផលិតវីដេអូ ស្តីពីសាកវប្បកម្ម

# ៤.១ ប្រភពព័ត៌មាន និងការស្ទង់មតិតាមបណ្តាញឌីជីថល

យើងបានធ្វើការស្ទង់មតិដើម្បីកំណត់ថាតើប្រភពព័ត៌មានទូទៅរបស់កសិករណាខ្លះជាកម្មវិធី ឬបណ្តាញឌីជីថលដែលពួកគេប្រើដើម្បីប្រមូល និងចែករំលែកចំណេះដឹង អត្ថប្រយោជន៍របស់ពួកគេ និងអ្វីដែលជាឧបសគ្គក្នុងការទាញយកឌីជីថលបន្ថែមទៀត។ ចំនួនអ្នកប្រើប្រាស់បណ្តាញអនឡាញនៅក្នុងប្រទេសកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័ស ហើយបណ្តាញទាំងនេះឥឡូវនេះគាំទ្រដល់ការភ្ជាប់ទំនាក់ទំនងអាជីវកម្ម និងសកម្មភាពទីផ្សារ។ មានកម្មវិធីជាច្រើននៅទីនោះ ហើយយើងខ្វះទិដ្ឋភាពទូទៅនៃមុខងាររបស់ពួកគេ ចំនួនអ្នកប្រើប្រាស់ ភាពស្និទ្ធស្នាលរបស់អ្នកប្រើប្រាស់ ការពេញចិត្តរបស់អតិថិជន និងនិន្នាភាព។ ដូចគ្នាដែរសម្រាប់បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា **Facebook, Telegram** និង **YouTube** ។ យើងក៏បានសួរកសិករអំពីប្រធានបទអ្វីដែលពួកគេចង់ទទួលបានព័ត៌មានបន្ថែមអំពី។

**ការស្រាវជ្រាវលើបណ្តាញឌីជីថលអាចត្រូវបានធ្វើឡើងតាមជំហានដូចខាងក្រោម:**

១. ចាប់ផ្តើមជាមួយនឹងការស្រាវជ្រាវឯកសារ ជាពិសេសដោយការអានការសិក្សាពីមុន និងរបាយការណ៍ស្តីពីកម្មវិធីកសិកម្មឌីជីថល ប្រសិនបើមាន។

២. ផ្អែកលើការស្រាវជ្រាវឯកសារ បង្កើតបញ្ជីកម្មវិធីទាំងអស់ និងគោលបំណងរបស់ពួកគេ អ្នកឧបត្ថម្ភ/ម្ចាស់មុខងារ ចំនួនអ្នកប្រើប្រាស់ ភាពស្និទ្ធស្នាលរបស់អ្នកប្រើប្រាស់ ថាតើពួកគេត្រូវបានកែលម្អជាទៀងទាត់ ចំណុចខ្លាំង និងចំណុចខ្សោយ។

៣. បង្កើតកម្រងសំណួរស្តីពីការប្រើប្រាស់បណ្តាញឌីជីថលសម្រាប់ក្រុមគោលដៅផ្សេងៗគ្នា។ កសិករអាចត្រូវបានសម្ភាសផ្ទាល់ដោយបុគ្គលិកផ្នែកបន្ថែមរបស់រដ្ឋាភិបាល ឬគម្រោង (បន្ទាប់ពីការបណ្តុះបណ្តាល និងការតំរង់ទិសពីមុន) ខណៈពេលដែលតួអង្គផ្សេងទៀតអាចត្រូវបានសម្ភាសន៍តាមទូរស័ព្ទ ឬអាចឆ្លើយតបតាមរយៈ Telegram ឬ WhatsApp ។ សូមមើលកម្រងសំណួរគំរូនៅក្នុងឧបសម្ព័ន្ធ 1 ។

៤. សាកល្បងកម្រងសំណួរជាមួយអ្នកឆ្លើយសំណួរមួយចំនួន។

៥. រៀបចំ និងធ្វើការស្ទង់មតិ និងសម្ភាសន៍។

៦. ប្រមូលផ្តុំ និងបញ្ចូលទិន្នន័យនៅក្នុងកម្មវិធីដែលសមស្រប (ឧ. Microsoft Excel) វិភាគ និងបកស្រាយវា និងសរសេររបាយការណ៍។

### លទ្ធផលនៃការស្ទង់មតិរបស់បណ្តាញឌីជីថល

យើងបានសម្ភាសកសិករចំនួន 117 នាក់ (ជ្រើសរើសដោយចៃដន្យពីបញ្ជីចំនួន 700) ដែលជាកម្មសិទ្ធិរបស់ក្រុមកសិករដែលគម្រោងឈេនបានធ្វើការជាមួយ។ ក្នុងចំណោមកសិករដែលបានសម្ភាសនោះ 41% មានអាយុលើសពី 45 ឆ្នាំ ដែលបង្ហាញពីនិន្នាការប្រជាជនវ័យចំណាស់ក្នុងចំណោមអ្នកធ្វើកសិកម្ម ខណៈដែលមានតែ 21% ប៉ុណ្ណោះដែលមានអាយុតិចជាង 35 ឆ្នាំ (70% ជាបុរស និង 30% ជាស្ត្រី)។

## ក. ក្រុមអាយុ និងការស្គាល់ឌីជីថលរបស់ពួកគេ

- ជាង 96% នៃកសិករកាន់កាប់ស្មាតហ្វូន។ មិនមានភាពខុសគ្នារវាងកសិករប្រុស និងស្រីក្នុងរឿងនេះទេ។
- 100% នៃកសិករវ័យក្មេង (អាយុ 15-45) និង 96% នៃកសិករវ័យចំណាស់ (អាយុ 45+) មានស្មាតហ្វូន។
- កសិករវ័យក្មេងចំនួន 79% បានឮអំពីកម្មវិធីកសិកម្មឌីជីថលដូចជា ទន្លេសាប ចំការ និងអង្គរសាឡាដ ប៉ុន្តែមានតែកសិករវ័យចំណាស់តែ 44% ប៉ុណ្ណោះដែលដឹងយ៉ាងហោចណាស់កម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងនេះ។
- ជាង 50% នៃកសិករវ័យក្មេង និងមួយភាគបីនៃកសិករវ័យចំណាស់បានប្រើប្រាស់កម្មវិធីយ៉ាងសកម្ម។ កសិករជាស្ត្រីមានទំនោរក្នុងការប្រើកម្មវិធីតិចជាងដៃគូបុរសរបស់ពួកគេ។




ដ្យាក្រាម ១៖ ការស្គាល់ប្រព័ន្ធឌីជីថលរបស់កសិករតាមក្រុមអាយុ

## ខ. ប្រភពចំណេះដឹង និងការសិក្សាកសិកម្ម

ជាការភ្ញាក់ផ្អើលរបស់យើង ស្មាតហ្វូន (22%) ត្រូវបានលើកឡើងថាជាប្រភពទូទៅបំផុតសម្រាប់កសិករ ក្នុងការទទួលបានព័ត៌មាន ទោះបីជាប្រភពផ្សេងទៀតដូចជាបុគ្គលិកផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាល (21%) អ្នកជិតខាង (20%) និងអង្គការក្រៅរដ្ឋាភិបាល (19%) គឺនៅជិត




ដ្យាក្រាម ២៖ ប្រភពចំណេះដឹង និងការរៀនកសិកម្ម

ការសិក្សាស៊ីជម្រៅទៅលើឥរិយាបថសិក្សារបស់កសិករ បានបង្ហាញថា កសិករវ័យក្មេងមួយចំនួនបានស្វែងរកយ៉ាងសកម្មនៅលើ YouTube សម្រាប់វីដេអូស្តីពីបច្ចេកទេសសាកវប្បកម្ម សត្វល្អិត និងជំងឺ ការធ្វើជីកំប៉ុស។ល។ពួកគេស្វែងរកវីដេអូជាភាសាក្នុងស្រុក ក្នុងករណីនេះជាភាសាខ្មែរ ប៉ុន្តែពួកគេក៏មើលផងដែរ វីដេអូជាភាសាផ្សេងទៀត ដោយសារមានការខ្វះខាតនៃវីដេអូដែលផ្តោតលើការដាំដុះ។ កសិករបានចង្អុលបង្ហាញថា ពួកគេនឹងស្វាគមន៍ការចែករំលែកបទពិសោធន៍ជាមួយក្រុមកាន់តែទូលំទូលាយ។ ការស្រាវជ្រាវរបស់យើងបង្ហាញថាប្រភពព័ត៌មានទូទៅបំផុតដែលមានតាមទូរស័ព្ទគឺជាកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលត្រូវបានប្រើប្រាស់រួចហើយដោយកសិករជាច្រើនសម្រាប់ទំនាក់ទំនងសង្គម។ នេះត្រូវបានបញ្ជាក់ដោយការស្រាវជ្រាវដែលធ្វើឡើងដោយក្រុមហ៊ុន Grow Asia Partnership ដែលបានរកឃើញថាកសិករប្រើប្រាស់ទូរស័ព្ទរបស់ពួកគេយ៉ាងសកម្មដើម្បីពង្រីកប្រតិបត្តិការកសិកម្មរបស់ពួកគេដោយរីកចម្រើនតាមរយៈដំណាក់កាលបួននៃការអនុម័តឌីជីថល៖

១. ការជួបផ្ទាល់: កសិករចាប់ផ្តើមដោយមិនមានបច្ចេកវិទ្យាឌីជីថលទាល់តែសោះ; ទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ អតិថិជន និងអ្នកផ្តល់ប្រាក់កម្ចីរបស់ពួកគេ ត្រូវបានធ្វើឡើងដោយផ្ទាល់។

២. ទូរស័ព្ទ៖ សព្វថ្ងៃនេះកសិករភាគច្រើនជំនួសការទំនាក់ទំនងទល់មុខគ្នាខ្លះជាមួយនឹងការហៅទូរស័ព្ទ។

៣. ការសន្ទនាជាក្រុម៖ នៅពេលដែលកសិករមានស្មាតហ្វូន ពួកគេមានទំនោរចូលរួមក្នុងការជជែកជាក្រុមតូចៗជាមួយមិត្តភក្តិរបស់ពួកគេនៅលើ WhatsApp, Line, Telegram ឬ Facebook Messenger។ ក្រុមទាំងនេះអនុញ្ញាតឱ្យកសិករស្វែងរកដំបូន្មានពីមិត្តភ័ក្តិរបស់ពួកគេ និងទទួលបានព័ត៌មានតម្លៃនិងផលិតផល។ នៅពេលដែលក្រុមទាំងនេះបង្កើតនៅលើបណ្តាញសង្គមដែលមានស្រាប់ កសិករប្រើប្រាស់ក្រុមដើម្បីទំនាក់ទំនងជាមួយមនុស្សដែលពួកគេស្គាល់។

៤. ការរកឃើញសកម្ម៖ ក្នុងជំហានជឿនលឿនបំផុត កសិករប្រើទូរស័ព្ទរបស់ពួកគេដើម្បីបង្កើតការតភ្ជាប់ថ្មីដែលពួកគេមិនអាចធ្វើដោយផ្ទាល់។ កសិករទាំងនេះកំពុងប្រើប្រាស់បច្ចេកវិទ្យាមិនត្រឹមតែដើម្បីចរចាជាមួយអ្នកផ្គត់ផ្គង់ និងអតិថិជនដែលមានស្រាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីកំណត់អត្តសញ្ញាណ និងទាក់ទងដៃគូប្រតិបត្តិការថ្មី។ ការស្វែងរកតាមអ៊ីនធឺណិត ការផ្សាយវីដេអូ និងការផ្ញើសារអនុញ្ញាតឱ្យកសិករពង្រីកបណ្តាញ និងចំណេះដឹងរបស់ពួកគេ។



[៣] Voutier, P. (2019). Driving agritech adoption: Insights from Southeast Asia’s farmers. Grow Asia Partnership.
**http://exchange.growasia.org/driving-agritech-adoption-insights-southeast-asias-farmers**

## គ. បណ្ដាញឌីជីថលប្រើដោយកសិករ

- កម្មវិធីដែលប្រើច្រើនជាងគេគឺ YouTube, Facebook និង Telegram។
- កសិករចំនួន 58 នាក់បានដឹងពីរបៀបប្រើប្រាស់កម្មវិធីកសិកម្មឯកទេស។
- កម្មវិធីកសិកម្មល្បីពីរគឺ បឹងទន្លេសាប និងអង្គរសាឡាដ។ ពួកគេត្រូវបានប្រើប្រាស់ដោយកសិករប្រហែលមួយភាគបី។




ដ្យាក្រាម ៣៖ បណ្ដាញឌីជីថលប្រើដោយកសិករ




ដ្យាក្រាម ៤៖ កម្មវិធីកសិកម្មប្រើដោយកសិករ

**App ដែលពេញនិយមប្រើប្រាស់ក្នុងប្រទេសកម្ពុជាមានដូចខាងក្រោម៖**

**ទន្លេសាប** ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុកម្ពុជា (AMK)។ វាមានគោលបំណងផ្តល់ចំណេះដឹងបច្ចេកទេសលើផលិតផលកសិកម្ម។ ភ្ជាប់កសិករជាមួយអ្នកផ្គត់ផ្គង់ជីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត កៅស៊ូគ្របរងប្លាស្ទីក ឧបករណ៍ដំណក់ទឹក និងផ្សេងៗទៀត និងជាមួយអ្នកជំនាញដើម្បីពិភាក្សាអំពីបញ្ហា និងដំណោះស្រាយទាក់ទងនឹងកសិកម្ម និងអនុញ្ញាតឱ្យកសិករបន្តតាមដានព័ត៌មានទាក់ទងនឹងកសិកម្ម។

**អង្គរសាឡាដ** មានគោលបំណងបង្កើនប្រសិទ្ធភាព និងទិន្នផលកសិកម្ម ដោយផ្តល់ទិន្នន័យអំពីដំណាំបន្លែ។ កម្មវិធីនេះរួមបញ្ចូលព័ត៌មានអំពីប្រព័ន្ធធារាសាស្ត្រ ជី និងការគ្រប់គ្រងដំណាំ។ ចំការ (ចំការ) មានគោលបំណងជួយកសិករបង្កើនចំណេះដឹងបច្ចេកទេសទាក់ទងនឹងការផលិតប្រចាំថ្ងៃ និងទទួលបានទីផ្សារកាន់តែប្រសើរឡើង ដោយភ្ជាប់ពួកគេជាមួយអ្នកផ្គត់ផ្គង់ និងអ្នកទិញ។

ចំការ

មានគោលបំណងជួយដល់កសិករបង្កើនចំណេះដឹងពីបច្ចេកទេសទាក់ទងទៅនឹងផលិតកម្មប្រចាំថ្ងៃ និងទទួលបានទីផ្សារប្រសើរឡើងតាមរយៈការផ្សាភ្ជាប់ពួកគាត់ជាមួយអ្នកផ្គត់ផ្គង់ និងអ្នកទិញ។

## ឃ. ប្រធានបទសិក្សា

យើងក៏បានសួរកសិករថាតើប្រធានបទណាដែលពួកគេចង់រៀនអំពី (សូមមើលឧបសម្ព័ន្ធទី 2 សម្រាប់សំណួរដែលយើងបានប្រើ)។ ប្រធានបទនៃការចាប់អារម្មណ៍ខាងក្រោមទទួលបានពិន្ទុខ្ពស់បំផុត៖

- សត្វល្អិត និងជំងឺប៉ះពាល់ដល់បន្លែផ្សេងៗគ្នា
- ភ្នាក់ងារត្រួតពិនិត្យជីវសាស្ត្រ (BCAs)
- វិធីដាំបន្លែក្នុងផ្ទះកញ្ចក់
- បច្ចេកវិទ្យាសន្សំសំចៃទឹក និងបូមទឹកដោយប្រើថាមពលពន្លឺព្រះអាទិត្យ
- ជីកំប៉ុស និងប្រើប្រាស់ជីគីមី

ផ្អែកលើការស្រាវជ្រាវនេះ ក្រុមមួយមានសមាសភាពពីបុគ្គលិកគម្រោងឈេន និងអ្នកតំណាងរដ្ឋាភិបាលតាមខេត្តគោលដៅបានកំណត់ថា YouTube គឺជាបណ្តាញដែលកសិករប្រើប្រាស់ញឹកញាប់បំផុត និងស្គាល់ពួកគេជាច្រើន។ កសិករចូលចិត្តមើលវីដេអូជាជាងរៀនពីរបៀបប្រើកម្មវិធីថ្មី។ វីដេអូខ្លីអាចជាឧបករណ៍ដ៏មានអានុភាព និងមានប្រសិទ្ធភាពក្នុងការផ្ទេរចំណេះដឹងដល់កសិករ ហើយវាក៏មានតម្លៃកម្សាន្តផងដែរ ទោះបីជាការផលិតវីដេអូប្រកបដោយវិជ្ជាជីវៈអាចមានតម្លៃថ្លៃក៏ដោយ។

វីដេអូផ្សព្វផ្សាយគួរតែខ្លី ងាយយល់ និងជាភាសាក្នុងស្រុក។ ពួកគេគួរតែបង្ហាញលក្ខខណ្ឌ និងកាលៈទេសៈក្នុងតំបន់ ហើយនិយមបង្ហាញកសិករក្នុងស្រុក និង/ឬបុគ្គលិកផ្នែកបន្ថែមពន្យល់ពីបច្ចេកទេស ឬការច្នៃប្រឌិតដែលកំពុងត្រូវបានណែនាំ។

យើងបានស្វែងរកវិធីបីយ៉ាងដើម្បីធ្វើឱ្យវីដេអូផ្សព្វផ្សាយរបស់កសិករមានតម្លៃថោក និងអាចចូលប្រើប្រាស់បានកាន់តែច្រើន៖

- ផលិតវីដេអូថ្មីៗដោយសហការជាមួយក្រុមហ៊ុនឯកជន
- បកប្រែវីដេអូ YouTube ដែលមានស្រាប់ទៅជាភាសាខ្មែរ
- បណ្តុះបណ្តាលកសិករក្នុងស្រុក និងបុគ្គលិកផ្សព្វផ្សាយឱ្យផលិតវីដេអូ។

# ៤.២ ផលិតវីដេអូអប់រំក្នុងភាពជាដៃគូជាមួយវិស័យឯកជន

ក្រុមហ៊ុនធាតុចូលសាកវប្បកម្មសង្ឃឹមថាកសិករនឹងទទួលបានបទពិសោធន៍វិជ្ជមាន (ដូចជាការទទួលបានទិន្នផលកាន់តែប្រសើរ និងទទួលបានប្រាក់ចំនូលកាន់តែច្រើន) នៅពេលប្រើប្រាស់ផលិតផលរបស់ពួកគេ ដូច្នេះក្រុមហ៊ុនជាច្រើនបានជួលអ្នកជំនាញកសិកម្ម និងបុគ្គលិកផ្នែកបន្ថែមដើម្បីរៀបចំផែនការសាកល្បង និងផ្សព្វផ្សាយផលិតផលរបស់ពួកគេជាមួយនឹងអ្នកលក់ធាតុចូល និងអ្នកលក់រាយ។ គម្រោងឈេនបានចូលជាដៃគូជាមួយក្រុមហ៊ុនគ្រាប់ពូជអន្តរជាតិជាច្រើនដូចជា East-West Seed,[៤] ដែលមានបទពិសោធន៍ក្នុងការផលិតវីដេអូសម្រាប់កសិករ។



គម្រោងឈេនក៏បានចាប់ដៃគូជាមួយក្រុមហ៊ុន VAHAY Seed,[៥] ដែលជាក្រុមហ៊ុនគ្រាប់ពូជកម្ពុជាប្ដេជ្ញាចិត្តក្នុងការអភិវឌ្ឍវិស័យកសិកម្មរបស់ប្រទេស ការបង្កាត់ពូជពូជថ្មី និងរក្សាវត្តមានយ៉ាងសកម្មនៅក្នុងតំបន់ជនបទ។ ក្រុមហ៊ុន VAHAY យល់ឃើញថា សត្វល្អិត និងជំងឺជាហានិភ័យដល់ការដាំបន្លែជោគជ័យ ដោយសារកង្វះចំណេះដឹង។ ការវិនិយោគលើការគ្រប់គ្រងសត្វល្អិតដែលប្រសើរឡើងនឹងធ្វើឱ្យកសិករកាន់តែទទួលបានជោគជ័យ ហើយនឹងនាំឱ្យតម្រូវការគ្រាប់ពូជកើនឡើង។ ប្រសិនបើកសិករមិនទទួលបានជោគជ័យក្នុងផលិតកម្មដោយសារសត្វល្អិត/ជំងឺ នោះពួកគេនឹងមិនពង្រីកផលិតកម្ម និងកំណត់តម្រូវការគ្រាប់ពូជនោះទេ។ បន្ទាប់ពីការសាកសួរពីគម្រោងឈេន និងក្រុមហ៊ុន VAHAY បានបង្ហាញចំណាប់អារម្មណ៍ក្នុងការផលិតវីដេអូទាក់ទងនឹងកសិកម្ម និងបង្ហាញពីផលិតផលរបស់ពួកគេ។ ដោយទទួលស្គាល់ថាជំងឺរុក្ខជាតិ និងសត្វល្អិតជាក្ដីកង្វល់យ៉ាងខ្លាំងចំពោះកសិករ ពួកគេបានយល់ព្រមចែករំលែកតម្លៃនៃការផលិតវីដេអូអប់រំស្ដីពីការគ្រប់គ្រងសត្វល្អិត និងជំងឺលើដំណាំ។



[៤] East-West **(www.eastwestseed.com)** is a vegetable seed company active in Southeast Asia and Africa. They offer a wide range of free videos on vegetable production. See **https://gvp.eastwestseedfoundation.org/farmers-learning-videos.**
[៥] Valang Phany Co., Ltd. (VAHAY) is a local seed company established in 2017. It seeks to create market demand for new products and provides smart farming extension services to farmers.

**ជំហានក្នុងការសហការផលិតវីដេអូអប់រំ៖**

១. យល់ព្រមជាមួយក្រុមហ៊ុនលើគោលបំណង ប្រធានបទ ទស្សនិកជនគោលដៅ កាលវិភាគ និងការចំណាយ។ កំណត់ចំណាំគោលគំនិតសាមញ្ញ និងកិច្ចព្រមព្រៀងសហការអាចត្រូវបានបង្កើតឡើងសម្រាប់រឿងនេះ។

២. ស្វែងរក និងជ្រើសរើសអ្នកថតវីដេអូដែលមានបទពិសោធន៍ ឬក្រុមហ៊ុនផលិតខ្សែភាពយន្តដែលមានសមត្ថភាពថតវីដេអូបច្ចេកទេស។ យើងសូមណែនាំឱ្យដៃគូវិស័យឯកជនធ្វើបែបនេះ ព្រោះពួកគេត្រូវចុះកិច្ចសន្យាផលិតវីដេអូ។ ការពិនិត្យមើលតម្លៃយោងត្រូវបានណែនាំ។

៣. ត្រូវប្រាកដថាអ្នកថតវីដេអូយល់ច្បាស់ពីគោលបំណងនៃវីដេអូ និងទស្សនិកជនគោលដៅ។

៤. យល់ព្រមលើអត្ថបទថត។ នេះនឹងតម្រូវឱ្យមានការសរសេរ ការកែសម្រួល និងការពិភាក្សាជាច្រើនដង។

៥. ថត និងកែសម្រួលវីដេអូ សាកល្បងវាសម្រាប់ការយល់ដឹងជាមួយទស្សនិកជនគំរូ និងធ្វើការកែតម្រូវតាមតម្រូវការ។

## គន្លឹះក្នុងការថតវីដេអូនៅទីវាល



១. ប្រសិនបើអ្នកចង់បង្ហាញវដ្តដំណាំពេញលេញ អ្នកប្រហែលជាត្រូវថតជាច្រើនខែ ឬនៅកន្លែងផ្សេងៗគ្នា។

២. ការថតពពួកសត្វល្អិត និងជំងឺអាចជាការពិបាក ព្រោះវាប្រហែលជាពិបាកក្នុងការស្វែងរកពួកវានៅក្នុងវាលស្រែ ឬចំការក្នុងដំណាក់កាលផ្សេងៗគ្នារបស់វា។ ដូច្នេះ យើងសូមណែនាំឱ្យប្រើរូបថត រូបដែលមានស្រាប់ (ប្រភពពីអ៊ីនធឺណិត ឬបណ្ណាល័យរូបភាព) នៃរោគសញ្ញាសត្វល្អិត និងជំងឺមួយចំនួន។

៣. ការបញ្ចប់វីដេអូនៅត្រង់សត្វល្អិតបំផ្លាញ និងអន្តរាគមន៍កំចាត់សត្វល្អិតត្រូវបានណែនាំ។

Access Agriculture is a platform for farmer-shot videos in many languages.
**https://www.accessagriculture.org/news/access-agriculture-videos-boost-farmer-training**

# ៤.៣ ការបកប្រែ/កែសម្រួលវីដេអូដែលមានស្រាប់

ប្រសិនបើថវិការបស់អ្នកមានកម្រិត អ្នកអាចជ្រើសរើសយកវីដេអូដែលមានស្រាប់ទៅនឹងបរិបទក្នុងតំបន់ដោយការបកប្រែសំឡេង ឬផ្តល់ចំណងជើងរងជាភាសារបស់អ្នក ដោយធ្វើតាមជំហានទាំងនេះ៖

១. កំណត់ប្រធានបទ និងគោលបំណងសិក្សា។

២. ស្វែងរកវីដេអូដែលមាននៅលើអ៊ីនធឺណិត។ YouTube និង Access Agriculture គឺជាប្រភពដ៏ល្អទាំងពីរ។

៣. វាយតម្លៃភាពសមស្របរបស់ពួកគេសម្រាប់បរិបទកម្ពុជា និងបង្កើតអនុសាសន៍អំពីរបៀបសម្របខ្លួនពួកគេ។ ឧទាហរណ៍ វីដេអូមួយអាចត្រូវបានកាត់បន្ថយដោយការលុបផ្នែកដែលមិនសមស្របនឹងគោលបំណងរបស់អ្នក ខណៈពេលដែលការថតនៅតែអាចត្រូវបានបញ្ចូលនៅកន្លែងដែលសមស្រប (ឧ. ការបិទបង្ហាញទិដ្ឋភាពលម្អិតនៃការបំផ្លាញដោយសត្វល្អិត)។

៤. កំណត់ថាតើវីដេអូដែលបានជ្រើសរើសនីមួយៗអាចត្រូវបានកែសម្រួល និងសមស្របសម្រាប់អ្នកប្រើប្រាស់ដោយសេរី។ បើមិនដូច្នោះទេ អ្នកប្រហែលជាត្រូវសរសេរទៅកាន់ម្ចាស់កម្មសិទ្ធិបញ្ញា ឬគេហទំព័រដែលបង្ហោះវីដេអូនេះ ដើម្បីទទួលបានការអនុញ្ញាត។

៥. បកប្រែអត្ថបទនៃការបញ្ចេញសំឡេងរបស់វីដេអូទៅជាភាសារបស់អ្នក ហើយថតសំឡេងថ្មីដោយប្រើអត្ថបទដែលបានបកប្រែ។

៦. ទាក់ទងអ្នកថតវីដេអូ ឬក្រុមហ៊ុនវីដេអូដែលមានបទពិសោធន៍ ដើម្បីកែសម្រួលវីដេអូ។

៧. ចែករំលែកវីដេអូដែលបានកែសម្រួលតាមរយៈបណ្តាញដូចជា YouTube, Facebook ឬគេហទំព័រផ្សេងទៀតដែលអ្នកគិតថាពួកវានឹងត្រូវបានចូលប្រើប្រាស់ និងមើលយ៉ាងងាយស្រួលដោយកសិករ។

៨. ផ្សព្វផ្សាយវីដេអូជាមួយកសិករម្នាក់ៗ ជាពិសេសអ្នកដឹកនាំកសិករ ហើយអនុញ្ញាតឱ្យពួកគេចែករំលែកវីដេអូជាមួយអ្នកដទៃនៅលើបណ្តាញសង្គមតាមរយៈក្រុម Telegram ក្រុម Messenger ជាដើម។

# ៤.៤ បណ្តុះបណ្តាលកសិករក្នុងស្រុក និងបុគ្គលិកផ្នែកផ្សព្វផ្សាយ ដើម្បីផលិតវីដេអូ

វីដេអូដែលបានថត និងកែសម្រួលដោយកសិករទំនងជាមានប្រសិទ្ធភាពខ្ពស់សម្រាប់ការពិភាក្សាក្នុងសហគមន៍ ការរៀនសូត្ររបស់កសិករ និងដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា។ យើងចង់ជំរុញកសិករឱ្យផលិត និងចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ពួកគេតាមរយៈវីដេអូ ជាពិសេសដើម្បីពន្យល់ពីបច្ចេកទេស និងផ្តល់ដំបូន្មាន។ វីដេអូទាំងនេះមានតម្លៃទាប ហើយត្រូវការតែស្មាតហ្វូន ពេលវេលារបស់កសិករ និងឆន្ទៈក្នុងការចែករំលែករបស់ពួកគេ។ យើងបានរៀបចំសម្រាប់កសិករ និងបុគ្គលិកផ្នែកផ្សព្វផ្សាយ ដែលត្រូវបានបណ្តុះបណ្តាលដោយអ្នកផលិតវីដេអូអាជីព ដែលមានបទពិសោធន៍ក្នុងការផលិតវីដេអូអប់រំខ្លី និងក្នុងការបណ្តុះបណ្តាល និងបង្វឹកអ្នកដទៃ។

## សូមអនុវត្តតាមជំហានទាំងនេះ ដើម្បីបង្រៀនកសិករពីរបៀបផលិតវីដេអូដោយខ្លួនឯង៖

១. បុគ្គលិករបស់គម្រោងដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយកសិករអាចពន្យល់ពីគំនិតនៃការបង្កើតវីដេអូដល់កសិករ និងកំណត់អ្នកដែលចាប់អារម្មណ៍ក្នុងការចូលរួម។ ជាមួយនឹងគម្រោងឈេនជាធម្មតាយើងជ្រើសរើសអ្នកចូលរួមតាមរយៈកសិករគម្រូ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកក្នុងតំបន់របស់គម្រោង។ យល់ព្រមលើទីកន្លែង និងពេលវេលាសម្រាប់ការបណ្តុះបណ្តាល និងផ្ញើការអញ្ជើញចូលរួម។

២. បង្កើតគោលបំណងសិក្សា និងពិភាក្សាអំពីប្រធានបទវីដេអូដែលអាចធ្វើទៅបានជាមួយកសិករ ក៏ដូចជារយៈពេលធម្មតានៃវីដេអូអប់រំមួយ។

៣. បង្រៀនកសិករពីរបៀបសរសេរអត្ថបទសម្រាប់ថត ការថត និងកាត់តវីដេអូដោយប្រើស្មាតហ្វូន ហើយបង្ហោះ និងចែករំលែកវីដេអូរបស់ពួកគេនៅលើ Telegram ឬប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត។ សូមមើលផ្នែកដែលត្រូវគ្នាខាងក្រោមសម្រាប់ការណែនាំលម្អិតអំពីជំហានសិក្សាទាំងនេះ។

៤. ប្រសិនបើអ្នកចូលរួមមួយចំនួនមិនទាន់មានស្មាតហ្វូនទេ សូមពិចារណាឱ្យពួកគេខ្ចីស្មាតហ្វូនពីគម្រោង ដើម្បីពួកគេអាចធ្វើការពិសោធន៍ជាមួយគ្នា ឬឧបត្ថម្ភធនលើការទិញស្មាតហ្វូន។

៥. ធ្វើវីដេអូបង្ហាញខ្លះៗ រួចទុកឲ្យកសិករធ្វើការពិសោធន៍បន្ថែម។

